# ប្រធានបទទី៦

# “ការប្រើប្រាស់សិទ្ធិអំណាច
# និងឆន្ទានុសិទ្ធិរបស់តុលាការ”

ថ្ងៃព្រហស្បតិ៍ ទី១៣ ខែមីនា ឆ្នាំ២០២៥

# មាតិកា

១. សេចក្តីផ្តើម

២. សារបាន និងសារៈសំខាន់នៃប្រធានបទ

៣. ក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនឹង "ឆន្ទានុសិទ្ធិ"

៤. ករណីសិក្សាចំនួន ៤ ករណី

៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ១. សេចក្តីផ្តើម

- សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់តុលាការ
  - យុត្តិធម៌តាមផ្លូវច្បាប់
  - យុត្តិធម៌ដែលសង្គមទទួលយកបាន
  - ការប្រើប្រាស់ឆន្ទានុសិទ្ធិដោយរំលោភបំពាន

# សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់តុលាការ

- តំណាងអយ្យការ (ចោទប្រកាន់, តាមដានការអនុវត្តទោស)
- ចៅក្រមស៊ើបសួរ (វិធានការនិរន្តរាយ, ដីកាដំណោះស្រាយ)
- ចៅក្រមជំនុំជម្រះ (ការសម្រេចសេចក្តីក្នុងរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ)

# ២. សារធាតុ និងសារៈសំខាន់នៃប្រធានបទ

- ការបកស្រាយច្បាប់
- ការការពារសិទ្ធិ
- ការធានានូវយុត្តិធម៌
- ការប្រើប្រាស់អំណាចធន្ទានុសិទ្ធិ
- សេចក្តីសម្រេចជាយុត្តិសាស្ត្រនៃតុលាការជាន់ខ្ពស់
- ការធានានូវគោលនយោបាយសាធារណៈ

# ៣. ក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនឹង "ឆន្ទានុសិទ្ធិ"

- រដ្ឋធម្មនុញ្ញ
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា
- ក្រមនីតិវិធីរដ្ឋប្បវេណី
- ក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្រមសីលធម៌ចៅក្រម

# “ចំពោះមុខចៅក្រម គឺនិយាយពីច្បាប់

# ចំពោះច្បាប់ គឺនិយាយពីយុត្តិធម៌”

ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

## មាត្រា ៤ ៖

បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ។



# ក. សិទ្ធិអំណាចរបស់តំណាងអយ្យការ

- ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និង សុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ (មាត្រា៤/ក.២ ក្រ.ន.ព.ទ.)
- ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ (មាត្រា២៧/ក.១ ក្រ.ន.ព.ទ.)
- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ (មាត្រា ៣៦ ក្រ.ន.ព.ទ.)

- មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា (មាត្រា១៣១ថ្មី រដ្ឋធម្មនុញ្ញ)
- បណ្ដឹងអាជ្ញា ត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ (មាត្រា៤/ក.១ ក្រ.ន.ព.ទ.)
- ជម្រើសនៃការចោទប្រកាន់ (មាត្រា៤០ ក្រ.ន.ព.ទ គោលការណ៍ការកាលានុវត្តភាព)
- ធ្វើបណ្ដឹងឧទ្ធរណ៍ (ដោយព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញា) (មាត្រា៣៧៥)
- ក្នុងការបំពេញកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ (មាត្រា២៧ ក.២ ក្រ.ន.ព.ទ.)
- ជានាដល់ការអនុវត្តទោស (មាត្រា៤៩៧ ក្រ.ន.ព.ទ.)
- អធិការកិច្ចពន្ធនាគារ (មាត្រា៥០៩ ក្រ.ន.ព.ទ.)
- បញ្ជាឱ្យបង្ខំ និង ឱ្យឃុំខ្លួន (មាត្រា៥២៦ ក្រ.ន.ព.ទ.)
- ចូលរួមនៅក្នុងគ្រប់នីតិវិធីព្រហ្មទណ្ឌ និង ជាពិសេស...សវនាការរឿងក្ដីព្រហ្មទណ្ឌ

# ខ. សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់ចៅក្រម

- សិទ្ធិអំណាចរបស់ចៅក្រម
  - មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី (មាត្រា១២៩ថ្មី ក.២ រដ្ឋធម្មនុញ្ញ)
  - មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី (មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ)

## ក. នៅក្នុងរឿងក្តីព្រហ្មទណ្ឌ

- ជម្រើសក្នុងការសម្រេចឃុំខ្លួន ឬ មិនឃុំ (មាត្រា២០៣ ឬ ២០៧ ក្រ.ន.ព.ទ)
- ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង (មាត្រា ១១០/ក.២ ក្រ.ន.ព.ទ.)
- ជម្រើសក្នុងការសម្រេចដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ឬ មិនសម្រេច (មាត្រា២១៥ ក.១ ក្រ.ន.ព.ទ)
- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ (មាត្រា២៤៧ថ្មី ក្រ.ន.ព.ទ)
- ការប្រកាសពីពិរុទ្ធភាពដោយចៅក្រមជំនុំជម្រះ (មាត្រា៣៥០ ក.២ និង ក.៣ ក្រ.ន.ព.ទ)
- ចៅក្រមត្រូវប្រឈមនឹង៖ ការប្តឹងជិតចិត្ត (មាត្រា៥៥៦ ក្រ.ន.ព.ទ), ការដកខ្លួន (មាត្រា៥៥៥ ក្រ.ន.ព.ទ), ការដកហូតសមត្ថកិច្ច (មាត្រា២៧ ក្រ.ន.ព.ទ)

## ខ. នៅក្នុងរឿងក្ដីរដ្ឋប្បវេណី៖

- ពិនិត្យកស្ដុតាងទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្ដីដោយឆន្ទានុសិទ្ធិ (មាត្រា១៦ ក្រ.ន.រ.ណ.)
- ផ្ទេរបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ចដោយឆន្ទានុសិទ្ធិ (មាត្រា១៨ ក.១, មាត្រា១៩ ក.១ ក្រ.ន.រ.ណ.)
- ស្រាវជ្រាវអត្ថិភាពនៃសិទ្ធិតំណាងដោយឆន្ទានុសិទ្ធិ (មាត្រា៥៧/ក.១ ក្រ.ន.រ.ណ.)
- កំណត់តម្លៃនៃកម្មវត្ថុបណ្ដឹងស្មុគស្មាញ ដោយឆន្ទានុសិទ្ធិ (មាត្រា៦០/ក.៣ ក្រ.ន.រ.ណ.)
- ស្រាវជ្រាវមធ្យោបាយ... ដោយឆន្ទានុសិទ្ធិតុលាការ (មាត្រា១០៨ ក្រ.ន.រ.ណ.)
- កម្រិតទៅលើសំណួរទៅលើការសួរសាក្សី... ដោយឆន្ទានុសិទ្ធិ (មាត្រា១៣៩/ក.៣ ក្រ.ន.រ.ណ.)

- ការថែរក្សាការពារកស្តុតាងដោយធន្ទានុសិទ្ធិ (មាត្រា១៦៧ ក្រ.ន.រ.ណ.)
- បង្គាប់ឱ្យបន្តនីតិវិធីនៃបណ្តឹង ដោយធន្ទានុសិទ្ធិ (មាត្រា១៧៦ ក្រ.ន.រ.ណ.)
- ការសម្រេចសេចក្តីនៅក្នុងរឿងរដ្ឋប្បវេណី (ដោយដីកាសម្រេច ឬ សាលក្រម មាត្រា១៧៩ ក្រ.ន.រ.ណ.)
- តុលាការចេញសាលក្រម តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (មាត្រា១៨៤ ក្រ.ន.រ.ណ.)
- ការប្រកាសថា សាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបាន ដោយធន្ទានុសិទ្ធិ (មាត្រា១៩៦ ក្រ.ន.រ.ណ.)
- ការកំណត់កាលបរិច្ឆេទ ដោយធន្ទានុសិទ្ធិ (មាត្រា២៤០ ក្រ.ន.រ.ណ.)
- ការបញ្ជូន ដោយធន្ទានុសិទ្ធិ (មាត្រា២៤៦ ក្រ.ន.រ.ណ.)

“ការដោះស្រាយវិវាទមិនមែនត្រឹមតែបានចេញសេចក្ដីសម្រេចប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានាថាសេចក្ដីសម្រេចនោះយកទៅអនុវត្តបាន និងបញ្ចប់វិវាទ។”

ប្រសាសន៍របស់ ឯកឧត្តមបណ្ឌិត ជីវ កេង ប្រធានតុលាការកំពូល

# ៤. ករណីសិក្សាចំនួន ៤ ករណី

ក. ករណីចាប់ជំរិតផ្ញើទៅខេត្តក្រចេះ (សមត្ថកិច្ចសាលាដំបូងភ្នំពេញ)

ខ. ករណីលក់កង់អេតចាយនៅខេត្តកណ្តាល

គ. ករណីលោកយាយនៅខេត្តតាកែវ

ឃ. ករណីវិវាទកាប់ដើមឈើនៅខេត្តកំពង់ឆ្នាំង

# ៤. ករណីសិក្សាទី១

## ក. ករណីចាប់ជំរិតផ្លែទៅខេត្តក្រចេះ (សមត្ថកិច្ចសាលាដំបូងភ្នំពេញ)

- *សំណុំរឿងព្រហ្មទណ្ឌលេខ៦៧៣១ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ*
- ជនត្រូវចោទត្រូវបានឃុំខ្លួនដោយសារតែយកផ្លែរបស់ថៅកែចេញពីផ្ទះ ដោយសារថៅកែមិនបានបើកប្រាក់ខែឱ្យខ្លួនដែលជាជនក្រីក្រ។
- ក្រោយពីមានប្រតិកម្មពីមហាជន ជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ជនរងគ្រោះក៏បានធ្វើការដកពាក្យបណ្ដឹងវិញ ហើយតំណាងអយ្យការក៏បានធ្វើដីកាសន្និដ្ឋានស្ថាពរស្នើសុំលើកលែងចោទប្រកាន់វិញ។

# ៤. ករណីសិក្សាទី២

## ខ. ករណីទិញកង់អេតចាយនៅខេត្តកណ្ដាល

- *សំណុំរឿងព្រហ្មទណ្ឌលេខ ២៣៤១ អ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល*
- ជនជាប់ចោទត្រូវបានឃុំខ្លួន ដោយសារតែទិញកង់អេតចាយដែលមិនដឹងប្រភពក្នុងតម្លៃ១០០០០ រៀល ហើយលក់វិញក្នុងតម្លៃ១១៥០០ រៀល ពោលគឺចំណេញ ១៥០០រៀល ប៉ុណ្ណោះ។
- ក្រោយពីមានប្រតិកម្មពីមហាជនលើការឃុំខ្លួនជនជាប់ចោទ ក្នុងដំណាក់កាលជំនុំជម្រះ តុលាការបានចេញសាលក្រមចាត់របៀប សម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នវិញ។

# ៤. ករណីសិក្សាទី៣

## គ. ករណីលោកយាយនៅខេត្តតាកែវ

- *សំណុំរឿងព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តតាកែវ*
- ដោយសារតែមិនព្រមអនុវត្តតាមអំណាចសាលដីកាស្ថាពរ លោកយាយព្រះជន្មជាង៨០ឆ្នាំ ត្រូវបានចាប់ខ្លួន ចោទប្រកាន់ និងឃុំខ្លួនរហូតដល់មានសាលក្រមស្ថាពរ។
- ក្រោយពីមានប្រតិកម្មពីមហាជន លោកយាយក៏បានធ្វើបណ្ដឹងសើរើទៅតុលាការកំពូល ហើយតុលាការកំពូលបានសម្រេចព្យួរទោសការអនុវត្តទោសវិញ ដោយផ្អែកលើគោលការណ៍មនុស្សធម៌។

# ៤. ករណីសិក្សាទី៤

## ឃ. ករណីវិវាទកាប់ដើមឈើនៅខេត្តកំពង់ឆ្នាំង

- *សំណុំរឿងព្រហ្មទណ្ឌលេខ២៦៣ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៧ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង*
- មនុស្សមួយគ្រួសារត្រូវបានសម្រេចផ្តន្ទាទោស និងឃុំខ្លួនតាមអំណាចសាលក្រមរបស់សាលាដំបូង ដោយសារតែការចូលទៅកាប់ដើមឈើ ២ដើម ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។
- ក្រោយពីមានប្រតិកម្មពីមហាជន និងក្រោយពីភាគីជនជាប់ចោទបានដាក់ពាក្យស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន តុលាការក៏បានចេញសាលក្រមលេខ ២១៣ (គ) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ សម្រេចលុបចោលការបញ្ជាក់ចូលស្ថាពរលើសាលក្រមកំបាំងមុខ, ទទួលបណ្ដឹងទាស់របស់ជនជាប់ចោទ និងអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្នលើជនជាប់ចោទទាំង៣អ្នកវិញ។

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. ការពង្រឹងក្រមសីលធម៌ចៅក្រម ទាំងក្នុងពេលបំពេញមុខងារ និងក្រៅពេលការងារ (ប្រការ ៧ នៃក្រមសីលធម៌ចៅក្រម)

២. ពង្រឹង និងយកចិត្តទុកដាក់ខ្ពស់ក្នុងការប្រើឆន្ទានុសិទ្ធិ

- ថ្លឹងថ្លែងឱ្យបានហ្មត់ចត់លើអង្គហេតុ អង្គច្បាប់ និងស្ថានភាពសង្គម

៣. ការទទួលខុសត្រូវរបស់ប្រធានតុលាការ ឬ ព្រះរាជអាជ្ញា

- ត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញា ឬចៅក្រម ក្នុងនាមជាប្រធានស្ថាប័ន

៤. ពង្រឹងវិធានការអធិការកិច្ច និងវិន័យចំពោះការប្រើប្រាស់ឆន្ទានុសិទ្ធិដោយបំពាន

# សូមអរគុណ!